# អ្នកពិឃាត មានកាំបិត, ឌុច មានប៊ិច

***ដោយ ឡូរ៉ា ម៉ាក់ដូណល់***

***ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩***

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

## *«ក្រពើចេះហែលទឹករួចស្រាប់ទៅហើយ»*

*ថ្ងៃនេះជនជាប់ចោទ កាំង ហ្កេចអ៊ាវ (ហៅ ឌុច) បានធ្វើកសិណសាក្សីពីការសម្លាប់អ្នកទោស ចំនួន ១២.០០០នាក់ដែលបានស្លាប់ក្រោមការគ្រប់គ្រងរបស់ ឌុច នៅក្នុងគុកទួលស្លែង (មន្ទីរស-២១) និងវាលពិឃាតបឹងជើងឯក ក្នុងអំឡុងរបបខ្មែរក្រហម ។ ក្នុងរយៈពេលប្រមាណជិត៦ម៉ោង ឌុច បានឆ្លើយតបនឹងសំណួរពីចៅក្រមអង្គជំនុំជម្រះដោយការពិនិត្យពិច័យយ៉ាងល្អិតបំផុត រហូតមកដល់ពេលនេះ ។ ប្រហែលជាដោយសារតែសារសំខាន់នៃប្រធានបទ ឬរយៈពេលសួរសំណួរវែង ដូច្នេះហើយសូម្បីតែចៅក្រមជាតិ ធូ មណី និង យ៉ា សុខន ដែលជាចៅក្រមកម្រនឹងចូលរួមមតិយោបល់ក្នុងអំឡុងដំណើរនីតិវិធីកាលពីខែមុននេះ ក៏បានចោទសួរសំណួរទៅកាន់ ឌុច ដែរ ។*

*នៅជាយក្រុងភ្នំពេញវាលពិឃាតបឹងជើងឯកនាពេលបច្ចុប្បន្ននេះ បានក្លាយជាសារមន្ទីរប្រល័យពូជសាសន៍មួយ ដែលមានបូជនីយដ្ឋានរំលឹកដួងវិញ្ញាណខ្មោចជនរងគ្រោះក្នុងរបបខ្មែរក្រហម រួមទាំងរណ្តៅសាកសពយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលមានភ្ជាប់ជាមួយនឹងស្លាកសញ្ញារៀបរាប់ពីចំនួនមនុស្សស្លាប់ ត្រូវបានរកឃើញនៅតាមរណ្តៅនីមួយៗ ។ ក្នុងអំឡុងរយៈពេលបំពេញតួនាទីជាប្រធានមន្ទីរស-២១ ដំបូង ឌុច បានជ្រើសយកបឹងជើងឯកមកធ្វើជាកន្លែងសម្លាប់អ្នកទោសធំរបស់ខ្លួន ដោយសារតែ ឌុច «ខ្លាចការឆ្លងរាតត្បាតជម្ងឺ»ពីសាកសពស្អុយរលួយរបស់អ្នកទោសរាប់រយនាក់ ដែលបានកប់នៅមន្ទីរស-២១ ។ ជាទូទៅខណៈពេលដែល ឌុច សម្រេចថា អ្នកទោសត្រូវបានសួរចម្លើយល្អិតល្អន់គ្រប់ជ្រុងជ្រោយ និងទទួលបានចម្លើយសារភាពគ្រប់គ្រាន់ហើយ ឌុច នឹងចេញបញ្ជាឲ្យយកអ្នកទោសទៅ «កម្ទេច» នៅបឹងជើងឯក ។ បើទោះបីជា ឌុច ទទួលយកការទទួលខុសត្រូវលើការសម្លាប់អ្នកទោសទាំងអស់នេះក៏ដោយ ក៏ ឌុច បានទទូចនិយាយថា ខ្លួនគ្រាន់តែអនុវត្តតាមបញ្ជារបស់ថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជាឲ្យសម្លាប់«ខ្មាំង»ទាំងអស់នេះតែប៉ុណ្ណោះ ។ ដូច្នេះ ឌុច បានអះអាងថា ខ្លួនគ្រាន់តែជា*

អ្នកសម្រេចពីពេលវេលា និងអនុវត្តទៅតាមបញ្ជាតែប៉ុណ្ណោះមិនមែនធ្វើជាអ្នកសម្លាប់ទេ ។ ក្រោយពីការមកដល់មន្ទីរស-២១ អ្នកទោសត្រូវបានចាត់ទុកជា«មនុស្សស្លាប់»រួចបាត់ទៅហើយ ។

ជួនកាលករណីលើកលែងនៅក្នុងដំណើរការប្រតិបត្តិទូទៅ (សួរចម្លើយ និងសម្លាប់អ្នកទោស) ក៏បានកើតមានឡើងដែរ ។ មានពេលខ្លះសមមិត្ត ហ៊ិ អនុប្រធានរបស់ ឌុច បានបញ្ជូនអ្នកទោស«មិនសំខាន់»ទៅសម្លាប់នៅបឹងជើងឯក បើទោះបីជាអ្នកទោសទាំងនោះមិនទាន់បានសួរចម្លើយក៏ដោយ ។ ការធ្វើបែបនេះគឺដើម្បីកុំឲ្យមានភាពកកស្ទះនៅមន្ទីរស-២១ ។ ឌុច បានចាត់ទុកការបញ្ជូនអ្នកទោសទៅសម្លាប់ទាំងមិនបានសួរចម្លើយ បែបនេះជាការគ្រប់គ្រងលើ«បញ្ជីកិច្ចការ»នៅក្នុង«បន្ទុកការងារ»របស់ខ្លួន ។ បន្ថែមលើនេះ មានករណីសម្លាប់អ្នកទោសយ៉ាងហោចណាស់៥ករណី ដែលត្រូវបានសម្លាប់ស្របពេលតែមួយខណៈពេលដែលមានការចេញសេចក្តីសម្រេចឲ្យនាំអ្នកទោសជាង១០០នាក់ រួមទាំងកម្មាភិបាលជាប់ពាក់ព័ន្ធនឹងខ្មាំងទៅសម្លាប់នៅបឹងជើងឯក ។ ការសម្លាប់អ្នកទោសក្នុងចំនួនតូចបានធ្វើឡើងមុននឹងកងទ័ពវៀតណាមចូលមករំដោះទីក្រុងភ្នំពេញ ខណៈពេលដែលថ្នាក់លើរបស់ ឌុច បានចេញបញ្ជាឲ្យសម្លាប់អ្នកទោសដែលនៅសេសសល់ទាំងប៉ុន្មានចោលទាំងអស់ ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ថ្នាក់លើរបស់ ឌុច បាន«ដោះលែង»មនុស្សប្រមាណ១៥នាក់ ដោយសារតែជំនាញរបស់អ្នកទាំងនោះដែលរួមមាន ជាងគំនូរ ពេទ្យព្យាបាលធ្មេញ ដែលសុទ្ធតែជាមនុស្សមានប្រយោជន៍ដល់បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសគឺមន្ទីរស-២១ ។ ឌុច បានបង្ហាញថា ជុំ ម៉ី អតីតជាងជួសជុលម៉ាស៊ីន និងជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលបានចូលរួមតាមដានអង្គសវនាការជាងរៀងរាល់ថ្ងៃ ក៏ជាអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសផ្សេងទៀតដែលបានដោះលែងដែរ ។ ដោយគ្មានប្រតិកម្មអ្វីទាំងអស់ ជុំ ម៉ី គ្រាន់តែងក់ក្បាលនៅកន្លែងអង្គុយរបស់ខ្លួនតែប៉ុណ្ណោះ ។ នៅពេលដែលកងទ័ពវៀតណាមវាយដណ្តើមចូលកាន់កាប់ទីក្រុងភ្នំពេញ អ្នកទោសទាំង៥នាក់ដែលបានរត់រួចរស់រានមានជីវិតមិនមែនដោយសារតែ ឌុច បានបង្ហាញពីភាពអាណិតអាសូរដល់អ្នកទោសទាំងនោះទេ ប៉ុន្តែគឺដោយសារ ឌុច បានរត់យករួចខ្លួនតែប៉ុណ្ណោះ ។

ក្រោយពីវាលពិឃាតបឹងជើងឯក បានចាប់ផ្តើមដំណើរការពេញលេញមក ក៏មានអ្នកទោសជាច្រើននាក់ទៀតបានស្លាប់នៅមន្ទីរស-២១ដដែល ដោយសារជម្ងឺ ភាពអត់ឃ្លាន ការបូមឈាម ឬក៏ការធ្វើទារុណកម្ម ។ ក្នុងករណីទាំងអស់នេះ អ្នកយាមគុកបានថតរូបអ្នកទោសដើម្បីបញ្ជាក់ថា អ្នកទាំងនោះមិនបានលួចរត់ទេ ។ ជាមួយគ្នានេះ ក្មេងៗជាច្រើននាក់ត្រូវបានសម្លាប់នៅមន្ទីរស-២១ជាជាងនៅបឹង

ជើងឯក ។ ឌុច បានគូសបញ្ជាក់ថា ក្មេងៗទាំងនោះត្រូវបានសម្លាប់ដោយបោកក្បាលនឹងដើមឈើ
ប៉ុន្តែ ឌុច បានបដិសេធថា គ្មានការបោះសម្លាប់ក្មេងទម្លាក់ពីលើដំបូងអាគារនោះទេ ពីព្រោះការធ្វើ
បែបនេះអាចនឹងរំលោភលើមាគ៌ាគោលនយោបាយដែលចែងថា ការសម្លាប់មនុស្សត្រូវតែរក្សាជាការ
សម្ងាត់ ។ បើទោះបីជាមានឯកសារគូសបញ្ជាក់ថាហេតុការណ៍នេះពិតជាបានកើតឡើងក៏ដោយ ក៏ ឌុច
នៅតែបដិសេធថា គ្មានការប្រើប្រាស់សត្វមានពិសដើម្បីសម្លាប់អ្នកទោសនៅមន្ទីរស-២១ឡើយ ។

ទាក់ទិននឹងវិធីសាស្ត្រប្រើប្រាស់ដើម្បីសម្លាប់អ្នកទោសនៅវាលពិឃាតបឹងជើងឯក ឌុច បានពន្យល់ថា
“ខ្ញុំមិនមែនជាមេគំនិតបង្កើតវិធីសាស្ត្រសម្លាប់អ្នកទោស ដែលពិឃាតបានអនុវត្តនោះទេ ។ ពិឃាត
អាចប្រើប្រាស់វិធីសាស្ត្រសម្លាប់អ្វីក៏បានឲ្យតែធ្វើយ៉ាងណាធានាថា អ្នកទោសត្រូវបានកម្ទេចចោលពិត
មែន” ។ ឌុច បាននិយាយថា ខ្លួនមិនដែលបង្រៀនកងពិសេសដែលទទួលបន្ទុកសម្លាប់អ្នកទោសពីវិធី
សាស្ត្រសម្លាប់មនុស្សឡើយ ពីព្រោះថា “សត្វក្រពើចេះហែលទឹករួចស្រាប់ទៅហើយ” ។ ពិឃាត
សម្លាប់អ្នកទោសត្រូវបានជ្រើសរើសដោយផ្អែកលើ“ប្រវត្តិរូបល្អ”មានន័យថា អ្នកទាំងនោះមានប្រវត្តិ
ស្មោះត្រង់នឹងបក្សកុម្មុយនីស្តកម្ពុជា ។ ឌុច អះអាងថា ខ្លួនមិនដែលមានវត្តមានចូលរួម និងពិនិត្យការ
សម្លាប់អ្នកទោសនៅបឹងជើងឯកទេ លើកលែងតែមានម្តងនោះថ្នាក់លើរបស់ ឌុច បានបញ្ជាឲ្យ ឌុច
ទៅត្រួតពិនិត្យមើលការសម្លាប់ ពីព្រោះថា អតីតសមាជិកបក្សកុម្មុយនីស្តកម្ពុជាជាន់ខ្ពស់ម្នាក់ គឺជាជន
រងគ្រោះ ។ ខណៈពេលដែលអ្នកទោសដែលមានឋានៈខ្ពស់ត្រូវបានសម្លាប់ ជាទូទៅអ្នកទាំងនោះ ត្រូវ
បានអារ-ក វះពោះ និងថតរូបទុក ដើម្បីទុកជាភស្តុតាងសម្រាប់មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយ
នីស្តកម្ពុជាបានឃើញយ៉ាងច្បាស់លាស់ថា អ្នកទោសទាំងនោះពិតជាបានស្លាប់យ៉ាងពិតប្រាកដមែន ។

ជាទូទៅ កងពិសេសប្រាប់ទៅកាន់អ្នកទោសនៅមន្ទីរស-២១ថា អ្នកទាំងនោះត្រូវផ្លាស់ទៅនៅកន្លែង
ឃុំខ្លួនថ្មី ។ មុននឹងធ្វើដំណើរ អ្នកទោសទាំងអស់ត្រូវបានចងភ្នែក និងដាក់ខ្នោះ រួចហើយក៏ធ្វើដំណើរ
តាមឡានបិទជិតមួយទៅកាន់បឹងជើងឯកនៅពេលយប់ ។ ពេលទៅដល់បឹងជើងឯក អ្នកទោសទាំងអស់
ត្រូវបាននាំទៅដាក់នៅក្នុងផ្ទះឈើមួយ រហូតដល់ពេលឮឈ្មោះរបស់ខ្លួនដែលត្រូវសម្លាប់ ដោយអ្នក
ទោសភាគច្រើនត្រូវបានអារ-ក ។ ហើយ ឌុច បានរៀបរាប់ថា អ្នកទោសជនជាតិបរទេសចំនួន
៨នាក់ត្រូវបាន“ដុតរំលាយឆ្អឹង”តាមបញ្ជាពីថ្នាក់លើ ។

នៅវាលពិឃាតបឹងជើងឯក បុគ្គលិកចំនួន៤នាក់ត្រូវទទួលបន្ទុកលើកិច្ចការជីក និងកប់រណ្តៅ រួមទាំងយាមការពាររណ្តៅកប់សាកសពផងដែរ ។ ខណៈពេលដែលត្រូវបានសំណូមពរឲ្យធ្វើការឆ្លើយតបនឹងឯកសារយោងមួយដែលបញ្ជាក់ថា អ្នកទោសត្រូវបានបង្ខំឲ្យជីករណ្តៅកប់សាកសពខ្លួនឯងនោះ ឌុច ដំបូងបានបដិសេធមិនធ្វើការឆ្លើយតប ប៉ុន្តែក្រោយមកក៏បានពន្យល់យ៉ាងខ្លីថា អ្នកទោសប្រហែលជា៥ភាគរយត្រូវបានបង្ខំឲ្យធ្វើដូច្នេះ ។ ចំណែកឯនៅមន្ទីរស-២១វិញ ឌុច បានអះអាងថា រណ្តៅកប់សាកសពតែងតែជីកសម្រាប់អ្នកទោស៣នាក់ ហើយបាននិយាយបន្ថែមទៀតថា ប្រសិនបើមានភស្តុ-តាងផ្ទុយពីនេះនោះ ឌុច មិនបដិសេធនឹងចំនួនតួរលេខនោះឡើយ ។

តាមធម្មតា ឌុច តែងតែនិយាយពីវិប្បដិសារី និងភាពទទួលខុសត្រូវរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ។ ឌុច បានពន្យល់ប្រាប់ពីភាពទទួលខុសត្រូវសម្រាប់ការសម្លាប់ជីវិតសពិឃាត ដែលបានអារ-កសម្លាប់អ្នកទោស ។ ឌុច បានបន្ថែមថា ពិឃាតគ្រាន់តែសម្លាប់មនុស្សដែលត្រូវបានចាត់ទុកថាជាមនុស្សគ្មានជីវិតតែប៉ុណ្ណោះ ប៉ុន្តែសម្រាប់ ឌុច វិញ គឺថា“ខ្ញុំមានប៊ិច” ។ ឌុច បានទទួលស្គាល់ថា ខ្លួនបានសរសេរកំណត់ត្រាចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបញ្ជូនទៅថ្នាក់លើ និងដើម្បីបន្តធ្វើការចាប់ខ្លួន និងសម្លាប់ ។ ឌុច ហាក់បីដូចជាមានទឹកមុខក្រៀមក្រំ ឬរំជើបរំជួលរហូតដល់ស្រក់ទឹកភ្នែកជាច្រើនលើកនៅថ្ងៃនេះ ។

ថ្ងៃស្អែក អង្គជំនុំជម្រះនឹងមិនដំណើរការដូចរាល់ដងទេ ពីព្រោះថា ថ្ងៃស្អែកគឺជាថ្ងៃបុណ្យជាតិ ។ ព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់រយៈពេល៣ម៉ោងសម្រាប់ក្រុមនីមួយៗ ដើម្បីធ្វើការចោទសួរសំណួរទៅកាន់ ឌុច នៅថ្ងៃច័ន្ទ ទាក់ទិនពីការសម្លាប់នៅមន្ទីរស-២១ និងវាលពិឃាតបឹងជើងឯក ។

## សន្និសិទ្ធិកាសែត

ក្រោយពីការពិភាក្សាគ្នាយ៉ាងក្តៅគគុកទាក់ទិនពី“ការលួចបំផ្លាញឯកសារ” និងពីការតែងតាំងរបស់ហែឡែន ចាវីស ជាប្រធានអង្គភាពជួយជនរងគ្រោះមក សន្និសិទ្ធិកាសែតរបស់អង្គភាពកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាថ្ងៃនេះ កាន់តែមិនមានសារសំខាន់ និងគួរឲ្យចាប់អារម្មណ៍អ្វីឡើយ ។ មន្ត្រីកិច្ចការសាធារណៈបានមានប្រសាសន៍ថា កាលវិភាគរបស់អង្គជំនុំជម្រះ

ចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា រហូតមកទល់ពេលនេះ បានចេញផ្សាយកាលពីដើមសប្តាហ៍នេះរួចហើយ ។ បន្ថែមលើនេះ ក្រុមមន្ត្រីទាំងនេះបានផ្តល់នូវការគូសបញ្ជាក់ដែលពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលមិនសូវមានសារសំខាន់ដោយអះអាងថា ការជាប់ឃុំរយៈពេល៨ឆ្នាំរបស់ ឌុច ដែលសម្រេចដោយតុលាការយោធាកម្ពុជាធ្វើឡើងដោយខុសច្បាប់ ។

យ៉ាងណាមិញ មន្ត្រីកិច្ចការសាធារណៈបានផ្តល់នូវតួរលេខស្ថិតិដ៏គួរឲ្យចាប់អារម្មណ៍ពីអ្នកចូលរួមតាមដានដំណើរការរបស់អង្គជំនុំជម្រះ ។ ចាប់តាំងពីអង្គជំនុំជម្រះរបស់ ឌុច ដំណើរការកាលពីថ្ងៃទី៣០ ខែមិនា មក សាលសវនាការទទួលបានអ្នកចូលរួមតាមដានអង្គជំនុំជម្រះក្នុងចំនួន១៩២នាក់ជាមធ្យមក្នុងមួយថ្ងៃ ដោយមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើអង្គជំនុំជម្រះនេះក្នុងដើមសប្តាហ៍ដំបូង ។ លើសពីនេះ ក្រុមមន្ត្រីបានបន្តរាយការណ៍ទៀតថា អង្គជំនុំជម្រះនៅតែទទួលបានការចាប់អារម្មណ៍ខ្លាំង នៅខែមិថុនា ដោយមានអ្នកចូលរួមតាមដានចំនួន១៦៣នាក់ក្នុងមួយថ្ងៃ ។ អង្គភាពកិច្ចការសាធារណៈ បានប្រកាសថា ខ្លួនកំពុងតែព្រាងគម្រោងផ្សព្វផ្សាយថ្មីមួយសម្រាប់ការចាប់អារម្មណ៍របស់ទស្សនិកជននៅឆ្នាំ២០០៩ និងឆ្នាំ២០១០ ដែលនឹងបង្ហាញពីការកើនឡើងនៃការយកចិត្តទុកដាក់តាមដានអង្គជំនុំជម្រះរបស់តុលាការខ្មែរក្រហម ។ ដោយកត់សម្គាល់ឃើញថាការចុះផ្សាយព័ត៌មានរបស់សហគមន៍អន្តរជាតិមានលក្ខណៈទូលំទូលាយ ដែលអង្គភាពកិច្ចការសាធារណៈតែងតែរងនូវការចោទសួរសំណួររាប់មិនអស់ពីបណ្តាប្រទេសជុំវិញពិភពលោកនោះមន្ត្រីកិច្ចការសាធារណៈបានសង្កត់ធ្ងន់ថា គន្លឹះសំខាន់ដែលទាក់ទាញអ្នកតាមដានដំណើរការរបស់អង្គជំនុំជម្រះគឺ ទូរទស្សន៍ និងវិទ្យុ ។ នាពេលបច្ចុប្បន្ននេះស្ថានីយ៍ទូរទស្សន៍របស់កម្ពុជាដ៏ពេញនិយមចំនួនពីរ បានធ្វើការផ្សព្វផ្សាយដំណើរការនីតិវិធីជារៀងរាល់ថ្ងៃ ។

សន្និសិទ្ទិកាសែតក្នុងថ្ងៃនេះ គឺធ្វើឡើងជាលើកទីបួន ដែលជាការប្រជុំប្រចាំសប្តាហ៍ជាទូទៅរបស់អង្គភាពកិច្ចការសាធារណៈ ។ មូលហេតុដែលអង្គភាពកិច្ចការសាធារណៈខិតខំប្រឹងប្រែងធ្វើឲ្យខ្លួនបានជួបជាមួយនឹងក្រុមអ្នកសារព័ត៌មាន នេះបង្ហាញឲ្យឃើញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការទាក់ទាញឲ្យការចាប់អារម្មណ៍របស់សាធារណជន លើកិច្ចការសំខាន់ៗរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើទោះបីជាអង្គភាពកិច្ចការសាធារណៈមិនមានរបាយការណ៍សំខាន់ដែលត្រូវរាយការណ៍ក៏ដោយ ។